## ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
## អភិបូជានៅអំពៅព្រៃ
## ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៨

*តើលោកនៅកន្លែងណា?*

អត្ថបទទី១៖ ១សម ៣,៣-១០
អត្ថបទទី២៖ ១ករ ៦,១៣-១៥.១៧-២០
ដំណឹងល្អ៖ យហ ១,៣៥-៤៤

បងប្អូនជាទីស្រឡាញ់!

យើងបាននឹកឃើញដល់ជីវិតថ្មីដែលយើងបានទទួល ដោយសារព្រះកុមារយេស៊ូ។ ឥលូវព្រះសហគមន៍បានឲ្យយើងចូលនៅក្នុងជីវិតធម្មតាប្រចាំឆ្នាំ ដែលជាជីវិតពិសេសដោយសារយើងកំពុងរស់នៅជាមួយព្រះយេស៊ូដែលធ្វើដំណើរជាមួយយើង។ អត្ថបទថ្ងៃនេះ ជាអត្ថបទត្រូវនឹងព្រះសហគមន៍ថ្មីៗ គឺព្រះយេស៊ូកំពុងបង្កើតព្រះសហគមន៍ថ្មី ដោយព្រះអង្គបានជ្រើសរើសសាវ័កដែលសុខចិត្តដើរជាមយយព្រះយេស៊ូ។ លោកយ៉ូហានបាទីស្ត បានធ្វើពិធីជ្រមុជទឹកឲ្យព្រះយេស៊ូ នឹងលោកយ៉ូហានប៉ាទីស្ទបានសម្លឹងមើល និងចង្អុលទៅព្រះយេស៊ូហើយនិយាយថា នេះជាព្រះគ្រីស្តដែលយើងកំពុងទន្ទឹងរង់ចាំ។ ក្រោយមកព្រះយេស៊ូបានមើលមនុស្សពីរនាក់ហើយសួរគេថា កំពុងរកអ្វីសម្រាប់ជីវិតផ្ទាល់ខ្លួន? នេះគឺព្រះអង្គបង្កើតទំនាក់ទំនងជាមួយគេ។ ឲ្យយើងនឹកឃើញ នៅថ្ងៃដែលយើងបានស្គាល់ព្រះយេស៊ូ នៅថ្ងៃដែលយើងបានស្គាល់ព្រះសហគមន៍នៅអំពៅព្រៃនេះ ដែលមានអ្នកគ្រូថារីដែលជាគ្រីស្តបរិស័ទមុនគេបង្អស់នៅទីនេះ ដូចជាយ៉ូហានបាទីស្ទម្យ៉ាងដែលបង្ហាញឲ្យបងប្អូននៅទីនេះចាប់ផ្តើមមើលព្រះយេស៊ូ ក្រោយមកព្រះយេស៊ូមានសំនួរដើម្បីចាប់ផ្តើមបង្កើតទំនាក់ទំនង។ នេះជារបៀបដែលព្រះយេស៊ូបានធ្វើ តាមរយៈអ្នកគ្រូថារីពីដើម ដើម្បីឲ្យបងប្អូននៅទីនេះស្គាល់ព្រះយេស៊ូខ្លះៗ។ យើងមានបងប្អូនខ្លះៗ ដែលចាប់ផ្តើមឆ្លើយដល់សំនួររបស់ព្រះយេស៊ូ **អ្នកទាំងពីរមករកអ្វី?** គេបានសួរថា **តើលោកនៅកន្លែងណា?** គេចង់ដឹងកន្លែងរបស់ព្រះយេស៊ូ។ នៅពេលព្រះយេស៊ូទទួលពិធីជ្រមុជទឹកហើយ ព្រះយេស៊ូដើរពីភូមិមួយទៅភូមិមួយ ព្រះយេស៊ូឥតមានកន្លែងស្នាក់នៅច្បាស់ ប៉ុន្តែព្រះយេស៊ូអញ្ជើញគេឲ្យគេស្គាល់កន្លែងព្រះយេស៊ូដោយមានព្រះបន្ទូលថា **សូមអញ្ជើញមកអ្នកនឹងឃើញ**។ ក្រោយមកគេទៅជាមួយព្រះយេស៊ូ គេដើរពីភូមិមួយទៅភូមិមួយជាមួយព្រះយេស៊ូ គេមើលឃើញរបៀបដែលព្រះយេស៊ូបង្កើតទំនាក់ទំនងជាមួយអ្នកភូមិ។ ព្រះយេស៊ូបានធ្វើដំណើរតាមភូមិ ដើម្បីនិយាយអំពីដំណឹងល្អដល់អ្នកក្រីក្រ ដល់អ្នកជំងឺ ដល់មនុស្សដែលអស់សង្ឃឹម ក្រោយមកគេមកច្រើនដើម្បីទទួលជីវិតថ្មី អ្នកខ្វាក់ភ្នែកគេមើលឃើញ អ្នកដែលពិការដៃជើង គេអាចដើរបាន អ្នកដែលថ្លង់គេអាចស្តាប់លឺ អ្នកដែលមានជំងឺគេបានជាសាស្បើយ។ គេសប្បាយចិត្ត ដោយសារគេឃើញព្រះយេស៊ូបានណែនាំឲ្យប្រជាជនដែលមានទុក្ខលំបាកជា

ច្រើនបានទទួលការសង្គ្រោះ បានទទួលសេចក្ដីសង្ឃឹម បានទទួលកម្លាំងថ្មី។ អ្វីដែលយើងបានឃើញ នៅរាត្រីព្រះយេស៊ូប្រសូតជាសេចក្ដីពិត។ នៅថ្ងៃនោះមានហោរាចារ្យ មានអ្នកគង្វាល មានប្រជាជនដែលបានមកមើលទារកដែលទើបនឹងប្រសូត ៣០ឆ្នាំក្រោយមកព្រះយេស៊ូបានដើរតាមភូមិនីមួយៗ ដើម្បីណែនាំឲ្យប្រជាជនទទួលសេចក្ដីសង្ឃឹម។ នៅទីនេះយើងឃើញផ្ទាល់ភ្នែក យើងមានព្រះសហគមន៍ហើយ យើងចាប់ផ្ដើមមានជីវិតហើយ យើងរកឃើញកន្លែងដែលព្រះយេស៊ូនៅ។ សព្វថ្ងៃព្រះយេស៊ូនៅក្នុងមនុស្សទាំងអស់ ព្រះយេស៊ូធ្លាប់មានព្រះបន្ទូលថា **ពេលយើងជួបជុំគ្នាពីរបីនាក់ដោយនាមខ្ញុំ ខ្ញុំគង់នៅជាមួយ**។ វត្តមានរបស់ព្រះយេស៊ូ យើងមើលឃើញរាល់សប្ដាហ៍ពេលយើងចូលអភិបូជា នៅពេលយើងស្ដាប់ព្រះបន្ទូលនេះជាព្រះយេស៊ូផ្ទាល់ដែលមានព្រះបន្ទូលមកយើងម្នាក់ៗ **សូមអញ្ជើញមកតាមខ្ញុំអ្នកនឹងបានឃើញ**។ នៅពេលយើងជួយបងប្អូនព្រះយេស៊ូគង់នៅ នៅពេលយើងអធិដ្ឋានព្រះយេស៊ូគង់នៅ ពេលយើងជួបជុំគ្នាស្ដាប់ព្រះបន្ទូលព្រះយេស៊ូគង់នៅ ដូច្នេះព្រះយេស៊ូអញ្ជើញឲ្យយើងទៅមើលតាមផ្ទះ តាមភូមិ ព្រះយេស៊ូគង់នៅជាមួយយើងម្នាក់ៗ។ ព្រះយេស៊ូមានវត្តមាននៅក្នុងមនុស្សទាំងអស់ ជាពិសេសមនុស្សដែលគ្មានទីពឹង ដូច្នេះពេលយើងជួយមនុស្សម្នាក់ដែលកំពុងពិបាក បីដូចជាយើងជួយព្រះយេស៊ូផ្ទាល់។ ព្រះសហគមន៍មានជីវិត ដោយសារយើងស្ដាប់ព្រះយេស៊ូដែលណែនាំឲ្យយើងទៅមើល។ ព្រះយេស៊ូមិនបាននៅក្នុងភូមិណាសារ៉ែតរហូតទេ ប៉ុន្តែព្រះអង្គបានដើរពីភូមិមួយទៅភូមិមួយ ដើម្បីមើលឃើញទុក្ខលំបាករបស់បងប្អូនឯទៀតៗ។

ហោរាចារ្យ បានដើរតាមផ្កាយដើម្បីទៅដល់កន្លែងដែលព្រះយេស៊ូប្រសូត គេមើលឃើញផ្កាយដោយសារគេបានចេញពីផ្ទះ ហើយសម្លឹងមើលផ្ទៃមេឃគេឃើញមានផ្កាយមួយមានពន្លឺប្លែក។ ដូច្នេះយើងដូចគ្នាដែរ យើងត្រូវតែចេញពីរបងផ្ទះរបស់យើង ដើម្បីមើលឃើញទុក្ខលំបាករបស់បងប្អូនឯទៀតៗ ដើម្បីរកឃើញកន្លែងដែលព្រះយេស៊ូណែនាំឲ្យយើងទៅ ដើម្បីឲ្យក្លាយជាព្រះបេះដូងស្រឡាញ់របស់ព្រះយេស៊ូតែម្ដង។ យើងឃើញព្រះយេស៊ូ ដែលកំពុងស្វាគមន៍មនុស្សទាំងអស់ ដែលមានបេះដូងជាសញ្ញាសម្គាល់នៃសេចក្ដីស្រឡាញ់ដល់កំពូលរបស់ព្រះអង្គ។ ព្រះយេស៊ូកំពុងស្វាគមន៍យើងនៅក្នុងសេចក្ដីស្រឡាញ់ នឹងណែនាំឲ្យយើងចេញដើម្បីបង្ហាញសេចក្ដីស្រឡាញ់ដល់បងប្អូនឯទៀតៗ។ ដូច្នេះនៅក្នុងរដូវធម្មតានេះ ឲ្យយើងយកចិត្តទុកដាក់ពីមួយថ្ងៃទៅមួយថ្ងៃទៅជាសេចក្ដី

ស្រឡាញ់របស់ព្រះយេស៊ូសម្រាប់បងប្អូនឯទៀតៗ។ យើងត្រូវការបើកត្រចៀក ឲ្យយើងស្ដាប់ទាន់អ្វីដែលព្រះយេស៊ូណែនាំឲ្យយើងធ្វើការក្នុងសេចក្ដីស្រឡាញ់។

ថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គគង់នៅជាមួយយើង ដើម្បីឲ្យព្រះសហាគមន៍របស់យើងទៅជាព្រះសហាគមន៍មួយយ៉ាងពិសេស ដែលយើងអាចជួបព្រះយេស៊ូពិតៗ។ អាម៉ែន៕